## គុណភាពនៃការអប់រំ

គុណភាពអប់រំផ្តោតជាសំខាន់លើបំណិនការងារអនុវត្តន៍ រួមទាំងទ្រឹស្តី និងការស្រាវជ្រាវបច្ចេកទេសកសិកម្ម ដែលជាសក្តានុពលភាពក្នុងការប្រកួតប្រជែងការងារវិស័យកសិកម្ម ដោយៈ

- បណ្តុះបណ្តាលតាមកម្មវិធីសិក្សាឆ្លើយតបនឹងតំរូវការជាក់ស្តែង និង ទទួលស្គាល់ពីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងអប់រំ យុវជន និងកីឡា
- ផ្តល់មធ្យោបាយសិក្សា និងកន្លែងអនុវត្តន៍ស្រាវជ្រាវ ដើម្បីទទួលចំណេះដឹងមានលក្ខណៈអនុវត្តន៍ជាក់ស្តែង និងបែបវិទ្យាសាស្រ្ត
- មានធនធានមនុស្សទាំងខាងក្នុងនិងក្រៅប្រកបដោយបទពិសោធន៍
- រៀបចំនិងដំណើរការប្រឡងចេញ វាយតំលៃការសិក្សា ត្រឹមត្រូវតាមគោលការណ៍ និងប្រកបដោយតម្លាភាព



ជាយុទ្ធសាស្រ្ត និស្សិតបានបញ្ចប់ការសិក្សាត្រូវមាន ៖

- សមត្ថភាពបច្ចេកទេសខ្ពស់
- សមត្ថភាពការងារខ្ពស់
- អាកប្បកិរិយា និងសីលធម៌ល្អ

## កសិដ្ឋានស្រាវជ្រាវ និង អនុវត្ត

ដើម្បីលើកកំពស់គុណភាពអប់រំ ក.ព.ល បានបំពាក់ឧបករណ៍សំរាប់ជំនួយក្នុងការបង្ហាត់បង្រៀនព្រមទាំងបានបង្កើតនូវកសិដ្ឋានជាច្រើនដូចជា កសិដ្ឋានចិញ្ចឹមត្រី ចិញ្ចឹមមាន់ ចិញ្ចឹមជ្រូក កសិដ្ឋានបណ្តុះផ្សិត បន្លែ ចំការឈើហូបផ្លែ មន្ទីរពិសោធន៍ បន្ទប់កំព្យូទ័រ បណ្ណាល័យ... ដើម្បីឱ្យនិស្សិត និងសាស្រ្តាចារ្យអនុវត្តន៍ និងស្រាវជ្រាវពង្រឹងគុណភាពចំណេះដឹងកសិកម្មប្រកបដោយសក្តានុពល ។

## អន្តេវាសិកដ្ឋាន កីឡាដ្ឋាន និងអាហារដ្ឋាន

ក.ព.ល មានអន្តេវាសិកដ្ឋានចំនួន៣ខ្នង ក្នុងនោះមួយខ្នងជាអាគារចាស់មាន ១៦បន្ទប់ និងអាគារថ្មី ចំនួន ២ខ្នង ស្មើនឹង ២៨បន្ទប់ ហើយអាចទទួលនិស្សិតដែលមកពីខេត្តឆ្ងាយ ឬតំបន់ដាច់ស្រយ៉ាលឱ្យស្នាក់នៅ ចំនួន ១២០ នាក់ និង មានអាគារសំរាប់ឱ្យសាស្រ្តាចារ្យ បុគ្គលិក និងភ្ញៀវសំរាកចំនួន ០២ ខ្នងមាន ១៦ បន្ទប់ (អាគារចាស់) និងអាគារថ្មី ១០ អាគារ មាន ២០ បន្ទប់ ។



ក.ព.ល មានអាគារអាហារដ្ឋាន ២ខ្នង សំរាប់និស្សិត និងមន្ត្រីរាជការ និងមានទីលានកីឡាបាល់ទាត់ និង បាល់ទះដែលជាកន្លែង ថែទាំសុខភាពយ៉ាងសំខាន់ ។

## អាសយដ្ឋាន


ក.ព.លស្ថិតនៅផ្លូវជាតិលេខ៦អា ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ប្រអប់សំបុត្រ ១៣១៩ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ ៖ ០២៣ ៣៩៥ ៣៩៤ / ០១២ ២៦៧ ០០៥

អ៊ីមែល ៖ info@pnsa.edu.kh

គេហទំព័រ ៖ www.pnsa.edu.kh

ប្រធានផ្នែក ទូរសព្ទ័ ៖ ០១២ ៧០៧ ៦៧៧ / ០១២ ៨៨៣ ០១៤

អ៊ីម៉ែល ៖ khannarith@mobitel.com.kh

អនុប្រធាន ១ ៖ ០១១ ៧៩៥ ៩៨១

២ ៖ ០១២ ៨៧៩ ៨២០


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



# សាលាជាតិកសិកម្មព្រែកលៀប

PREK LEAP NATIONAL SCHOOL OF AGRICULTURE

# ផ្នែកបណ្តុះបណ្តាលបន្ត

# Division of Continuing Education



មករា ២០០៦

# ផ្នែកបណ្តុះបណ្តាលបន្ត

## ១.បេសកកម្ម

ជាភ្នាក់ងារសំរបសំរួលនិងគ្រប់គ្រងការបណ្តុះបណ្តាលកម្មវិធីសិក្សាបន្តក្នុងវិស័យកសិកម្ម និងវិស័យពាក់ព័ន្ធគ្រប់កំរិត ព្រមទាំងផ្តល់នូវសេវាប្រឹក្សា ការបណ្តុះបណ្តាលវគ្គខ្លី-វែង ការស្រាវជ្រាវ កម្មសិក្សា និងកម្មវិធីសហការអភិវឌ្ឍន៍របស់សាលាជាតិនៅតំបន់ជនបទតាមបណ្តាខេត្ត ។

## ២. គោលបំណង

ថ្នាក់បណ្តុះបណ្តាលបន្ត ត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីពង្រឹងពង្រីកសមត្ថភាព និងផ្តល់ឱកាសដល់មន្ត្រីរាជការ និស្សិត អាចបន្តការសិក្សាថ្នាក់បរិញ្ញាបត្ររង ឬ បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម បង្កើនប្រសិទ្ធភាពការងារ កាត់បន្ថយភាពក្រីក្រ លើកកំពស់ជីវភាព និងសេដ្ឋកិច្ចប្រជាពលរដ្ឋ ។

## ៣. យុទ្ធសាស្ត្រ

ថ្វីបើផ្នែកបណ្តុះបណ្តាលបន្ត ពុំមានដេប៉ាតឺម៉ង់ក្រោមឱវាទ ប៉ុន្តែ ផ្នែកធ្វើការសំរបសំរួលនិងសហការយ៉ាងជិតស្និទជាមួយផ្នែកជំនាញក្នុងនិងក្រៅសាលាជាតិ ព្រមទាំងជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម និងវិស័យពាក់ព័ន្ធ ។

## ៤. រចនាសម្ព័ន្ធផ្នែកបណ្តុះបណ្តាលបន្ត




# កម្មវិធីសំរាប់សិក្សា

## ១-ថ្នាក់បរិញ្ញាបត្រ *មានរយៈពេល ៤ ឆ្នាំ (១៥២ ក្រេឌីត)*

១.១- វិទ្យាសាស្ត្រកសិកម្ម

១.២- វិទ្យាសាស្ត្រជលផល

១.៣- វិទ្យាសាស្ត្រព្រៃឈើ

១.៤- សាកវប្បកម្ម

១.៥- សេដ្ឋកិច្ចកសិកម្ម

១.៦- វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ

១.៧- ផ្សព្វផ្សាយកសិកម្ម និងអភិវឌ្ឍន៍សហគមន៍ជនបទ

## ២-ថ្នាក់បរិញ្ញាបត្ររង *មានរយៈពេល ២ ឆ្នាំ (៨៦ ក្រេឌីត)*

២.១- ក្សេត្រសាស្ត្រ

២.២- ជលផល

២.៣- រុក្ខកម្ម

២.៤- ផលិតកម្ម និងបសុព្យាបាល

២.៥- សាកវប្បកម្ម

២.៦- បច្ចេកវិទ្យាម្ហូបអាហារ

២.៧- សេដ្ឋកិច្ចកសិកម្ម

២.៨- ផ្សព្វផ្សាយកសិកម្ម និងអភិវឌ្ឍន៍សហគមន៍ជនបទ

២.៩- សុរិយោដី

## ៣-លក្ខខណ្ឌសិក្សា: ទទួលនិស្សិតសិក្សាតាមកម្មវិធីសិក្សា:

- ថ្នាក់បរិញ្ញាបត្រចំនួន ២ ឆ្នាំបន្ត ចំពោះនិស្សិតមានសញ្ញាបត្របរិញ្ញាបត្ររង លើជំនាញដូចគ្នា ឬប្រហាក់ប្រហែល
- ថ្នាក់បរិញ្ញាបត្រ ៤ ឆ្នាំ ចំពោះនិស្សិតថ្មី (មានមធ្យមទុតិយភូមិ)
- បរិញ្ញាបត្ររង ១ ឆ្នាំកន្លះ ចំពោះនិស្សិតមានសញ្ញាបត្រថ្នាក់ភ្នាក់ងារកសិកម្មឬសញ្ញាបត្រតំលៃស្មើនឹងរយៈពេល ២ ឆ្នាំចំពោះនិស្សិតថ្មី។
- សាលាជាតិមានកម្មវិធីទទួលនិស្សិតដែលមានជំនាញផ្សេងក្រោមការវាយតំលៃក្រេឌីតពីគណៈកម្មការបច្ចេកទេសនៃ ក.ព.ល។

## ៣. ម៉ោងសិក្សា

សាលាជាតិកសិកម្មព្រែកលៀប

ទទួលនិស្សិតគ្រប់ប្រភេទតាមម៉ោងសិក្សា ដូចខាងក្រោម:

- ពេញម៉ោង: ច័ន្ទ-សុក្រ (៨:០០-១២:០០ និង ១៣:០០-១៧:០០)
- ក្រៅម៉ោង: សៅរ៍-អាទិត្យ (៧:៣០-១១:៣០ និង ១៣:០០-១៧:០០)

## ៤. វគ្គបណ្តុះបណ្តាលខ្លី (រយៈពេល ១-៤ សប្តាហ៍)



៥.១- បច្ចេកទេសចិញ្ចឹមត្រីសាច់

៥.២- បច្ចេកទេសផលិតកូនត្រីពូជ

៥.៣- ការគ្រប់គ្រងកសិដ្ឋាន

៥.៤- ការគ្រប់គ្រងដំណាំចំរុះ

៥.៥- ផលិតកម្មដំណាំបន្លែ

៥.៦- ផលិតកម្មដំណាំផ្សិត

៥.៧- ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ

៥.៨- ការផ្សព្វផ្សាយកសិកម្ម

៥.៩- ការកែច្នៃម្ហូបអាហារ

៥.១០- វិធីសាស្ត្របណ្តុះបណ្តាលកសិកម្ម

៥.១១- ផែនការ និងការគ្រប់គ្រងគំរោង

៥.១២- ការវាយតំលៃតាមជនបទដោយមានការចូលរួម

៥.១៣- ការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍នេសាទ

៥.១៤- ការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍ព្រៃឈើ

៥.១៥- វិធីសាស្ត្រស្រាវជ្រាវ

៥.១៦- ការគ្រប់គ្រងធនធានធម្មជាតិ